# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៤៣ អនក្រ.បក

### ស្តីពីការបង្កើត វិទ្យាស្ថានគ្រប់គ្រងនិងសេដ្ឋកិច្ច

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

មាត្រា ១ ._ អនុញ្ញាតអោយបង្កើតវិទ្យាស្ថានឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថានគ្រប់គ្រង និងសេដ្ឋកិច្ច ( Institute of Management and Economy ) ហៅកាត់ " វ.គ.ស " ។ វិទ្យាស្ថាននេះ មានទីតាំងនៅ អាគារលេខ ៥៥ ភូមិដំណាក់ហ្លួង ឃុំ វត្តគរ ស្រុក ស្វាយប៉ោ ខេត្តបាត់ដំបង ។

មាត្រា ២ ._ វិទ្យាស្ថាន គ្រប់គ្រង និងសេដ្ឋកិច្ច ធ្វើការ បណ្តុះបណ្តាល ថ្នាក់ បរិញ្ញាបត្រ [illegible]ៈពេលសិក្សា ៤ ឆ្នាំ ។

មាត្រា ៣ ._ វិទ្យាស្ថាន គ្រប់គ្រង និងសេដ្ឋកិច្ច មានមហាវិទ្យាល័យពីរ :

-មហាវិទ្យាល័យគ្រប់គ្រង

-មហាវិទ្យាល័យសេដ្ឋកិច្ច

ក្នុងវិទ្យាស្ថាននេះ មានវគ្គបណ្តុះបណ្តាល ជំនាញ រយៈពេលខ្លី ដូចជា ជំនាញគណនេយ្យ កុំព្យូទ័រ និងភាសាអង់គ្លេស ។ ក្នុងពេលអនាគត វិទ្យាស្ថាន អាចបើកមហាវិទ្យាល័យ រឺ ជំនាញ ឯកទេស ផ្សេងៗ ទៀត ដោយរៀបចំ សំណុំបែបបទ សុំការអនុញ្ញាតពី ក្រសួង អប់រំយុវជន និងកីឡា ។

មាត្រា ៤ ._ លក្ខខ័ណ្ឌទទួលសិស្សអោយចូលរៀន :

www.pheakdeylaw.com

-បេក្ខជនទាំងពីរភេទ ជា សិស្ស និស្សិត ប្រជាពលរដ្ឋ និង មន្ត្រីរាជការ .

-បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ

-បេក្ខជនត្រូវឆ្លង កាត់ការ ប្រលងតេស្ត ។

មាត្រា ៥ ._ នាយក វិទ្យាស្ថាន គ្រប់គ្រង និងសេដ្ឋកិច្ច មានភារកិច្ច

-ជ្រើសរើសសិស្សអោយចូលរៀន និង ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន

-គ្រប់គ្រងអោយបានល្អនូវការបង្រៀននិងកិច្ចការសិក្សាការប្រលងនិងការប្រគល់សញ្ញាប័ត្រ

-គោរព និង អនុវត្ត តាមសារាចរ និងសេចក្ដីណែនាំ របស់រាជរដ្ឋាភិបាល

-ធានាអោយបាន នូវសុវត្ថិភាព និងសណ្ដាប់ធ្នាប់សង្គម

-ធ្វើរបាយការណ៍ ពាក់ព័ន្ធសកម្មភាពសិក្សាជូន ក្រសួងអប់រំ យុវជន និងកីឡា ប្រចាំឆមាស និមួយៗ

មាត្រា ៦ ._ វិទ្យាស្ថានមានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកគ្រប់គ្រងវិទ្យាស្ថាននេះ ។

មាត្រា ៧ ._ នៅក្នុងវិទ្យាស្ថាននេះ មានក្រុមប្រឹក្សាវិទ្យាសាស្ត្រ មួយ ដែលមានសមាជិកយ៉ាងតិច ៣ នាក់ ដែលមានសញ្ញាប័ត្រម៉ាស្ទ័រ យ៉ាងទាប ក្នុងមុខជំនាញ របស់វិទ្យាស្ថាន សំរាប់ពិនិត្យ និងផ្ដល់ការយល់ព្រម លើ កម្មវិធីសិក្សា នៅដើមឆ្នាំ សិក្សានីមួយៗ ។

មាត្រា ៨ ._ ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើ អធិការកិច្ច និងត្រួតពិនិត្យ លើការងារបណ្ដុះបណ្ដាល ហើយមានសិទ្ធិស្នើសុំបិទ ប្រសិនបើវិទ្យាស្ថាននេះអនុវត្តខុសពីច្បាប់រដ្ឋ ។

មាត្រា ៩ ._ និស្សិតដែលរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ ហើយបានទទួលជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា នឹងបានទទួលសញ្ញាប័ត្រ ថ្នាក់បរិញ្ញាប័ត្រ ដែលផ្ដល់អោយដោយវិទ្យាស្ថាន គ្រប់គ្រង និង សេដ្ឋកិច្ចហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ដោយអនុវត្តតាម និតិវិធីអប្បបរមា នៃការទទួលស្គាល់ គុណភាពបណ្ដុះបណ្ដាលកំរិតឧត្ដមសិក្សា ។

មាត្រា ១០ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានគ្រប់គ្រងនិងសេដ្ឋកិច្ច មានភារកិច្ចរៀងៗខ្លួនដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

មាត្រា ១១ ._ អនុក្រឹត្យនេះមានប្រសិទ្ធភាព និង គតិយុត្ត ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃ ១៧ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

www.pheakdeylaw.com